# តម្រូវការផ្នែកកិច្ចការពារ និងការអប់រំ

## សម្រាប់កុមារ និងក្មេងជំទង់ នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ

សេចក្តីសង្ខេប




unicef

for every child

## គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងកំណត់ពីហានិភ័យសំខាន់ៗទាក់ទងនឹងកិច្ចការពារដែលកុមារក្នុងវ័យរៀននៅមត្តេយ្យសិក្សា (៣-៥ ឆ្នាំ) និងក្មេងជំទង់ (១០-១៤ ឆ្នាំ) ជួបប្រទះ និងកំណត់ពីទំនាក់ទំនងរវាងហានិភ័យទាំងនេះជាមួយនិងការអប់រំ។ ក្រៅពីនេះការសិក្សាក៏កំណត់ផងដែរនូវកត្តារាំងស្ទះ និងកត្តាអំណោយផល ដែលរារាំង ឬ សម្របសម្រួលឲ្យកុមារទាំងនេះទទួលបានការអប់រំប្រកបដោយគុណភាព។ ការសិក្សានេះក៏ពិនិត្យមើលផងដែរនូវប្រភេទសេវាកម្មនានា និងកង្វះនូវសេវាសម្រាប់ឆ្លើយតបនឹងតម្រូវការផ្នែកកិច្ចការពារ និងការអប់រំរបស់កុមារនៅតាមសហគមន៍ក្រីក្រ។ ការពិនិត្យមើលទៅលើសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងការឆ្លើយតបទៅនឹងបញ្ហាទាំងនេះក៏ជាគោលបំណងសំខាន់មួយទៀតនៃការសិក្សានេះដែរ។

## របកគំហើញសំខាន់ៗ

### ហានិភ័យសំខាន់ៗ ពាក់ព័ន្ធនឹង កិច្ចការពារកុមារ



ហានិភ័យសំខាន់ៗពាក់ព័ន្ធនឹងកិច្ចការពារកុមារ ដែលត្រូវបានរកឃើញក្នុងសហគមន៍ ហើយដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងភាពក្រីក្រ និងការខ្វះការថែទាំឲ្យបានគ្រប់គ្រាន់ពីសំណាក់ឪពុកម្តាយ រួមមាន ការប្រើបំពានសារធាតុ ការចូលរួមក្នុងក្រុមយុវជនទំនើង ដែលនាំឲ្យមានទំនាស់នឹងច្បាប់ ការដាក់ទណ្ឌកម្មលើរាងកាយ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការបំពានផ្លូវភេទ អាពាហ៍ពិពាហ៍កុមារ និងពលកម្មកុមារ។ បន្ថែមពីលើហានិភ័យទាំងនេះ កុមារ និងក្មេងជំទង់ ក៏មានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាថែទាំសុខភាព និងអនាម័យផងដែរ ហើយជារឿយៗ ពុំមានបរិក្ខាររូបវន្តជាមូលដ្ឋានសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ដូចជាបង្គន់ និងទឹកស្អាតសម្រាប់ផឹកឡើយ។ ក្រុមដែលកាន់តែងាយរងគ្រោះជាងគេ រួមមានកុមារ និងក្មេងជំទង់ដែលមានពិការភាព កុមារកំព្រា និងកុមារត្រូវបានគេបោះបង់ចោលគ្មានទីជម្រក។ កុមារ និងក្មេងជំទង់ដែលមានពិការភាព ជារឿយៗ គឺជាក្រុមដែលត្រូវបានគេផាត់ចេញពីក្របខ័ណ្ឌសង្គម។

### ភាពក្រីក្រ និង ហានិភ័យសំខាន់ៗ ដែលកុមារ និងក្មេង ជំទង់តាមសហគមន៍ ក្រីក្រក្នុងទីក្រុង ជួបប្រទះ មានទំនាក់ទំនង នឹងគ្នាយ៉ាងជិតស្និទ្ធ



ភាពក្រីក្រ និងហានិភ័យសំខាន់ៗ ដែលកុមារ និងក្មេងជំទង់តាមសហគមន៍ក្រីក្រក្នុងទីក្រុង ជួបប្រទះ មានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។ ការមានប្រាក់ចំណូលទាបមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការថែទាំកុមារមិនបានដិតដល់ពីសំណាក់ឪពុកម្តាយឬអាណាព្យាបាល ដោយសារពួកគាត់ត្រូវចំណាយពេលភាគច្រើនរកចំណូលដើម្បីបំពេញតម្រូវការជាមូលដ្ឋានក្នុងគ្រួសារ។ ការប្រើបំពានសារធាតុញៀន ក្នុងចំណោមអ្នកឆ្លើយតបជាក្មេងជំទង់ ត្រូវបានរកឃើញថាកើតមានច្រើន ដោយពួកគេប្រមាណជា ៨១,៤ ភាគរយ (ស្រី ៧៥,២ ភាគរយ និងប្រុស ៨៨,២ ភាគរយ) លើកឡើងថាពួកគេជាអ្នកប្រើជាតិស្រវឹង (ជាពិសេស ស្រាបៀរ)។ អ្វីដែលរឹតតែសំខាន់ទៅទៀតគឺ ៤៣,៨ ភាគរយនៃក្មេងជំទង់ (ស្រី ២៦,៦ ភាគរយ និងប្រុស ៦១,0 ភាគរយ) ដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ បានប្រើប្រាស់គ្រឿងញៀន (ជាពិសេស កញ្ឆា ហេរ៉ូអ៊ីន និងមេតំហ្វេតាមីន) យ៉ាងហោចណាស់ម្តង ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ។ ការប្រើបំពានសារធាតុញៀន ក៏មានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងការចូលជាសមាជិកក្នុងក្រុមយុវជនទំនើងផងដែរដោយក្រុមទំនើងទាំងនេះ តែងតែប្រព្រឹត្តអំពើហិង្សា និងវាយតប់គ្នា។ ក្មេងជំទង់ជាងពាក់កណ្តាល (៥២,៤ ភាគរយ) ដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញមានមិត្តភក្តិ ឬអ្នកស្គាល់គ្នា (ក្នុងក្រុមដែលមាន

អាយុស្របាលគ្នា) ជាសមាជិករបស់ក្រុមទំនើងណាមួយ។ អំពើហិង្សាក្នុងគ្រួសារក៏ជាករណីដែលតែងកើតឡើងញឹកញាប់ផងដែរ។ ក្មេងប្រុសប្រមាណជា ៦៥,៩ ភាគរយ និងក្មេងស្រី ៦៥,៣ ភាគរយ លើកឡើងថា ពួកគេធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារ (ក្នុងរយៈពេល ១២ ខែចុងក្រោយនេះ) កើតឡើងក្នុងផ្ទះ ឬក្នុងសហគមន៍។ អាពាហ៍ពិពាហ៍កុមារ គឺជាហានិភ័យសំខាន់មួយទៀត ហើយមានគ្រួសារ ៤,៩ ភាគរយរាយការណ៍ថា ពួកគេបានរៀបការឲ្យក្មេងជំទង់ចេញពីគ្រួសារ មុនពេលដែលពួកគេអាយុ ១៤ ឆ្នាំ។ ខណៈដែលអត្រានៃពលកម្មកុមារដែលបានរកឃើញក្នុងការសិក្សានេះមានកម្រិតទាបជាងកម្រិតមធ្យមនៅថ្នាក់ជាតិ អត្រាទាបបែបនេះកើតឡើងដោយសារតែអ្នកឆ្លើយតបមានការស្ទាក់ស្ទើរមិនចង់ឆ្លើយសំណួរ ព្រោះពួកគេដឹងថា ពលកម្មកុមារគឺជាសកម្មភាពខុសច្បាប់។

## ឧបសគ្គសំខាន់ៗ ដែលរាំងស្ទះដល់ការទទួលបានការអប់រំ និងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងសាលារៀន



ឧបសគ្គសំខាន់ៗ ដែលរាំងស្ទះដល់ការទទួលបានការអប់រំ និងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងសាលារៀន រួមមានការបង្រៀនមានគុណភាពទាប ភាពចាំបាច់ក្នុងការបង់ប្រាក់ក្រៅផ្លូវការ ការដាក់ទណ្ឌកម្មលើរាងកាយ ការសំឡុត គំរាម និងការខ្វះខាតសម្ភាររូបវន្ត សម្រាប់បំពេញតម្រូវការរបស់កុមារពិការ។ កត្តាទាំងនេះនាំមកនូវផលអវិជ្ជមានមួយចំនួនដូចជាអត្រាចុះឈ្មោះចូលរៀនទាបនៅកម្រិតមត្តេយ្យសិក្សា ការចូលរៀនមានកម្រិតទាប ការបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់នៅកម្រិតមធ្យមសិក្សា ជាដើម ។ បើទោះបីទាំងកុមារ និងឪពុកម្តាយសុទ្ធតែមានបំណងប្រាថ្នាខ្ពស់ពាក់ព័ន្ធនឹងការអប់រំ  ក៏ការចុះឈ្មោះចូលរៀននៅកម្រិតមត្តេយ្យសិក្សាក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងនៅមានកម្រិតទាប ដោយមានកុមារអាយុពី ៣ ទៅ ៥ ឆ្នាំត្រឹមតែ ២៩ ភាគរយប៉ុណ្ណោះ បានចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យក្នុងទម្រង់ណាមួយ។ ខណៈដែលអត្រាចុះឈ្មោះចូលរៀនមានការកើនឡើងក្នុងចំណោមកុមារមកពីសហគមន៍ក្រីក្រដែលមានអាយុច្រើនជាងនេះ  ដែលក្នុងនោះក្មេងជំទង់អាយុពី ១០ ដល់ ១៤ ឆ្នាំ ប្រមាណជា ៨៥,០ ភាគរយ បានចុះឈ្មោះចូលរៀនតាមសាលារៀនក្នុងប្រព័ន្ធក្តី ក៏អត្រាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាមានការកើនឡើងផងដែរ។ ក្នុងចំណោមក្មេងជំទង់ ដែលបោះបង់ចោលការសិក្សាកាលពីពេលថ្មីៗនេះ ៨៧,៥ ភាគរយ បានលើកឡើងថា ពួកគេធ្លាប់បានចូលរៀន។ ការខ្វះការយកចិត្តទុកដាក់ពីគ្រូ ក៏ដូចជាភាពចាំបាច់ក្នុងការបង់ថ្លៃក្រៅផ្លូវការឬការផ្តល់ប្រាក់ដល់គ្រូ គឺជាឧបសគ្គសំខាន់ៗ ដែលបន្ទុចបង្អាក់ដល់ការចូលរៀន និងការបន្តរៀនសូត្រតាមសាលារៀននានា។ ដោយហេតុថាពួកគេកំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្ររួចទៅហើយនោះ ឪពុកម្តាយមិនអាចមានលទ្ធភាពបង់ថ្លៃសេវាក្រៅផ្លូវការបានឡើយ។ ការដែលគ្រូបង្រៀនមិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ រួមនឹងបញ្ហាប្រាក់បៀវត្សរ៍ទាបផងនោះ ធ្វើអោយការបង្រៀនរបស់គាត់មិនសូវមានគុណភាពដែលនេះជាឧបសគ្គមួយចំពោះការផ្តល់ការអប់រំប្រកបដោយគុណភាព។ លើសពីនេះ ការខ្វះការបណ្តុះបណ្តាលអំពីរបៀបទំនាក់ទំនងជាមួយសិស្សមានពិការភាព គឺជាបញ្ហាប្រឈមដ៏ចំបងមួយ ចំពោះការបង្កើតបរិយាកាសដែលមានបរិយាប័ន្ន (មានការចូលរួមពីកុមារពិការ) ក្នុងសាលារៀន។ ការដាក់ទណ្ឌកម្មលើរាងកាយ និងការរករឿងឈ្លោះ ក៏កើតមានជាទូទៅតាមសាលារៀនក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងផងដែរ។ សិស្ស ២៥,៧ ភាគរយបានលើកឡើងថា ធ្លាប់ទទួលរងការរករឿងឈ្លោះក្នុងសាលារៀន ហើយក្នុងចំណោមក្មេងជំទង់ដែលធ្លាប់ទៅសាលារៀន មាន ៣០,៥ ភាគរយ រាយការណ៍ ថាធ្លាប់ទទួលរងការដាក់ទណ្ឌកម្មលើរាងកាយ។

# គម្រូការផ្នែកកិច្ចការពារ និងការអប់រំសម្រាប់កុមារនិងក្មេងជំទង់នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ

## ការបីបាច់របស់ឪពុកម្តាយ

កុមារនិងក្មេងជំទង់នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញជួបប្រទះនូវហានិភ័យនិងការខ្វះខាតច្រើនយ៉ាងដោយសារតែភាពក្រីក្រក្នុងគ្រួសារ។ របាយការណ៍នេះបង្ហាញនូវការពាក់ព័ន្ធគ្នាយ៉ាងជិតស្និទរវាងភាពក្រីក្រនិងការប្រឈមនឹងហានិភ័យ។ ដោយសារតែឪពុកម្តាយ ឬអាណាព្យាបាលបានចំណាយពេលច្រើនលើសលប់ទៅលើការរកចំណូលផ្គត់ផ្គង់គ្រួសារ ពួកគាត់មានពេលតិចតួចបំផុតសម្រាប់មើលថែបីបាច់កូនៗរបស់គាត់។ គួបផ្សំនឹងការយល់ដឹងរបស់ពួកគាត់នៅមានកម្រិតផងនោះ ម្ល៉ោះហើយគ្រួសាររបស់គាត់កាន់តែមានលទ្ធភាពតិចតួចក្នុងការការពារកុមារពីហានិភ័យ បញ្ជូនកូនៗទៅសាលាជាប្រចាំ ធានាឲ្យពួកគេទទួលបានអាហារប្រកបដោយជីវជាតិ និងសេវាចាំបាច់ផ្សេងៗទៀត។




ក្មេងជំទង់ប្រមាណ ៤៨% បាននិយាយថាពួកគេមានការប្រាស្រ័យទាក់ទងតិចតួចជាមួយឪពុកម្តាយ ឬអាណាព្យាបាល

## កិច្ចការពារកុមារ

ការប្រើបំពានសារធាតុញៀន ការចូលរួមក្នុងក្រុមយុវជនទំនើង ការដាក់ទណ្ឌកម្មរាងកាយ អំពើហិង្សាក្នុងគ្រួសារ ការបំពារបំពានផ្លូវភេទ អំពើហិង្សាលើកុមារ អាពាហ៍ពិពាហ៍ក្មេងជំទង់មិនទាន់គ្រប់វ័យ និងពលកម្មកុមារ សុទ្ធតែជាហានិភ័យដែលបានរកឃើញក្នុងការសិក្សានេះហើយដែលកំពុងប្រឈមដោយកុមារនិងក្មេងជំទង់រស់នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ។




ក្មេងជំទង់ប្រមាណ ៥២% បាននិយាយថាមានមិត្តភ័ក្តនៅក្នុងក្រុមយុវជនទំនើង




ក្មេងជំទង់ប្រមាន ៨១% (ក្មេងស្រី ៧៥% និងក្មេងប្រុស ៨៨%) បានរាយការណ៍ថាបានផឹកគ្រឿងស្រវឹង




ក្មេងជំទង់ប្រមាន ៤៤% (ក្មេងស្រី ២៦,៦% និងក្មេងប្រុស ៦១%) រាយការណ៍ថាបានប្រើប្រាស់គ្រឿងញៀនយ៉ាងហោចណាស់ម្តងក្នុងរយៈពេលមួយឆ្នាំកន្លងមក។




ឪពុកម្តាយឬអាណាព្យាបាលប្រមាណ ៦០% បានប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយជាការដាក់វិន័យលើកូនរបស់ខ្លួន




ក្មេងជំទង់ប្រមាន ៦៦% (ក្មេងស្រី ៦៥% និងក្មេងប្រុស ៦៦%) រាយការណ៍ថាបានឃើញករណីអំពើហិង្សាក្នុងគ្រួសារ




គ្រួសារប្រមាណ ២២% បានដឹងពីករណីអំពើហិង្សាលើកុមារ




គ្រួសារប្រមាណ ១៥% រាយការណ៍ថាបានដឹងពីករណីកុមារ ឬក្មេងជំទង់ដែលត្រូវបានគេបោះបង់ចោលហើយដែលបច្ចុប្បន្នកំពុងរស់នៅតាមដងផ្លូវ

# ការអប់រំ

មានបញ្ហាប្រឈមមួយចំនួនដែលរារាំងកុមារនិងក្មេងជំទង់រស់នៅតាមសហគមន៍ក្រីក្រពីការទទួលបានការអប់រំប្រកបដោយគុណភាព។ ឧបសគ្គទាំងនោះរួមមាន ភាពក្រីក្រ បញ្ហាសុខភាព ពិការភាព ការយល់ដឹងរបស់ឪពុកម្តាយឬអាណាព្យាបាលនៅមានកម្រិត ទឹកចិត្តរបស់គ្រូមានកម្រិត និងការចំណាយមិនផ្លូវការផ្សេងៗទៀត។




កុមារក្នុងក្រុមអាយុ ៣ ទៅ ៥ឆ្នាំប្រមាណ ២៩% បានចូលរៀននៅថ្នាក់មត្តេយ្យក្នុងនោះកុមារីមាន ៣២%




ក្មេងជំទង់ប្រមាណ ២៦% បានជួបប្រទះករណីរករឿងឈ្លោះនៅសាលា




53% of adolescents are paying informal fee to teachers

# ពិការភាព

កុមារនិងក្មេងជំទង់ដែលមានពិការភាពរស់នៅតាមសហគមន៍ក្រីក្រ ជាក្រុមដែលងាយរងគ្រោះបំផុត។ អត្រាចុះឈ្មោះចូលរៀនក្នុងចំណោមពួកគេមានកម្រិតទាប ហើយសាលារៀនមិនមានហេដ្ឋារចនាសម្ព័ន្ធ និងធនធានសមស្រប (ដូចជាគ្រូមានជំនាញ) សម្រាប់ជួយដល់ការសិក្សារបស់កុមារនិងក្មេងជំទង់ឡើយ




កុមារដែលមានពិការភាព ៥៩% និងក្មេងជំទង់មានពិការភាពប្រមាណ ២៨,៦% មិនបានចុះឈ្មោះចូលរៀននៅសាលាណាមួយទេ




ឪពុកម្តាយរបស់កុមារមានពិការភាពប្រមាណ ៧៨% និងឪពុកម្តាយរបស់ក្មេងជំទង់ ដែលមានពិការភាពប្រមាណ ៨២% គិតថាគ្រូបង្រៀនរបស់កូនពួកគាត់ពុំមានជំនាញសម្រាប់បង្រៀនកូនគាត់ដែលមានពិការភាពនោះទេ




ឪពុកម្តាយរបស់កុមារមានពិការភាពប្រមាណ ៨៩% និងឪពុកម្តាយរបស់ក្មេងជំទង់ដែលមានពិការភាពប្រមាណ ៩០%គិតថាសាលារៀនពុំមានហេដ្ឋារចនាសម្ព័ន្ធនិងបរិក្ខារសមស្របចាំបាច់សម្រាប់ជំនួយដល់សិស្សដែលមានពិការភាពទេ

---

របកគំហើញពីការសិក្សានេះគូសបញ្ជាក់ថា ការថែទាំបីបាច់ត្រឹមត្រូវពីឪពុកម្តាយឬអាណាព្យាបាលចំពោះកូននិងការប្រាស្រ័យទាក់ទងជិតដល់ជាមួយកូនៗគឺជាគន្លឹះចំបងបំផុតក្នុងការបង្ការកុមារនិងក្មេងជំទង់ពីហានិភ័យនានា និងក្នុងការធានាថាកូនៗទទួលបានសេវាចាំបាច់នានា។ ដូច្នេះ គប្បីមានការយកចិត្តទុកដាក់ដល់អន្តរាគមន៍ណាដែលលើកកំពស់ដល់ការថែទាំជិតដល់របស់ឪពុកម្តាយឬអាណាព្យាបាលចំពោះកូនៗរបស់ពួកគេ ព្រោះអន្តរាគមន៍បែបនេះនឹងអាចជួយដោះស្រាយបញ្ហាបានច្រើន ដែលរកឃើញក្នុងការសិក្សានេះ។

---

## អនុសាសន៍

អនុសាសន៍ចេញពីការស្រាវជ្រាវនេះ ផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការពង្រឹងការងារសំខាន់ៗនៅកម្រិតសាលារៀន កម្រិតសហគមន៍ និងថ្នាក់ជាតិ ដូចជាៈ

- ការរៀបចំអន្តរាគមន៍សម្រាប់ដោះស្រាយបញ្ហាអំពើហិង្សា ការរករឿងឈ្លោះ ការអប់រំផ្លូវភេទ និងការបំពានសារធាតុញៀន ដោយការបញ្ចូលមេរៀនពាក់ព័ន្ធនឹងបញ្ហាទាំងនេះក្នុងកម្មវិធីសិក្សា។
- យុទ្ធនាការផ្លាស់ប្តូរឥរិយាបថតាមសហគមន៍ ដែលផ្តោតការយកចិត្តទុកដាក់លើការប្រើបំពាន សារធាតុ ការដាក់ទណ្ឌកម្មលើរាងកាយ អាពាហ៍ពិពាហ៍ របស់ក្មេងជំទង់ អំពើហិង្សាលើកុមារ និងការជួញដូរមនុស្ស
- បង្កើតក្រុមសុវត្ថិភាពសហគមន៍ ដើម្បីការពារ និងថែរក្សា សន្តិសុខ និងសុវត្ថិភាពក្នុងសហគមន៍។
- ការបណ្តុះបណ្តាលសមាជិកស្ថាប័នពង្រឹងការអនុវត្តច្បាប់
- គំនិតផ្តួចផ្តើមទាក់ទងនឹងផ្នែកតម្រូវការ និងការផ្គត់ផ្គង់ ដើម្បីបង្កើនលទ្ធភាពទទួលបានទឹកស្អាត
- ការប្រែក្លាយសហគមន៍ក្រីក្រក្នុងទីក្រុងជាសហគមន៍ដែលពុំមានការបន្ទោរបង់ពាសវាលពាសកាល
- ការចុះបញ្ជី និងការគ្រប់គ្រងមណ្ឌលកុមារកំព្រា ឬមណ្ឌលថែទាំកុមារ
- ការចូលរួមរបស់អង្គការសង្គមស៊ីវិលលើការងារសវនកម្មសង្គម និងធានាឲ្យមានការអនុលោមតាមបញ្ញត្តិច្បាប់
- ការបណ្តុះបណ្តាលក្រុមប្រឹក្សាកុមារ និងបុគ្គលជំនាញផ្នែកសង្គមកិច្ច។
- ការរៀបចំមាគ៌ាអាជីពសម្រាប់គ្រូបង្រៀន
- ការបង្កើនប្រសិទ្ធភាពការងារនៃគណៈកម្មាធិការពិនិត្យតាមដានការងារសាលារៀន
- ការកែលម្អយន្តការបណ្តុះបណ្តាលគ្រូដែលមានស្រាប់
- ការបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន
- ការបង្កើតក្របខ័ណ្ឌពិនិត្យតាមដានសិទ្ធិកុមារ សម្រាប់រាជធានីភ្នំពេញ។

## វិធីសាស្ត្រ

កាសិក្សានេះប្រើប្រាស់វិធីសាស្ត្រចម្រុះដោយមានទាំងបែបគុណវិស័យផង និងបរិមាណវិស័យ។ ក្រុមវាយតម្លៃបានប្រើប្រាស់កម្រងសំណួរគ្រួសារដែលបានរៀបចំទុកជាមុន ការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធ និងការពិភាក្សាក្រុម ជាមួយអ្នកពាក់ព័ន្ធជាក់លាក់។ កម្រងសំណួរគ្រួសារ ត្រូវបានប្រើប្រាស់ជាឧបករណ៍បែបបរិមាណវិស័យ សម្រាប់សួរអ្នកពាក់ព័ន្ធសំខាន់ៗ ដូចជាឪពុកម្តាយឬអាណាព្យាបាលកុមារ (អាយុពី ៣ ដល់ ៥ ឆ្នាំ) និងក្មេងជំទង់ (អាយុពី ១០ ដល់ ១៤ ឆ្នាំ)។ ចម្លើយពីការអង្កេតនេះ បង្កើតបានជាទិន្នន័យ ដែលត្រូវយកទៅបញ្ជាក់ផ្ទៀងផ្ទាត់ និងវិភាគបន្ថែមទៀតដោយប្រើប្រាស់ឧបករណ៍បែបគុណវិស័យ ដូចជា ការពិភាក្សាក្រុមគោលដៅជាមួយនឹងសមាជិកសហគមន៍ ឪពុកម្តាយឬអ្នកថែទាំកុមារ និងក្មេងជំទង់អាយុពី ១០ ដល់ ១៤ ឆ្នាំ ក៏ដូចជាការសម្ភាសដោយប្រើសំណួរព្រាងទុកជាមុនផង និងមិនបានព្រាងទុកជាមុនផង ជាមួយនឹងតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល គ្រូបង្រៀនមកពីតាមសាលារៀននានាក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង និងមន្ត្រីរដ្ឋាភិបាលមកពីតាមក្រសួងពាក់ព័ន្ធសំខាន់ៗ។

កម្រងសំណួរត្រូវបានប្រើប្រាស់ជាមួយនឹងអ្នកឆ្លើយតបចំនួន ១១៩០ នាក់ ដែលត្រូវបានជ្រើសរើសជាសំណាក ក្នុងនោះមានឪពុកម្តាយឬអាណាព្យាបាលកុមារអាយុពី ៣ ដល់ ៥ ឆ្នាំចំនួន ៣៨០ នាក់ និងឪពុកម្តាយឬអាណាព្យាបាលក្មេងជំទង់អាយុពី ១០ ដល់ ១៤ ឆ្នាំចំនួន ៣៨០ នាក់ ដោយមានក្មេងស្រីជំទង់ចំនួន ១៩០ នាក់ និងក្មេងប្រុសជំទង់ ១៩០ នាក់ ក្នុងក្រុមអាយុ ១០ ដល់ ១៤ ឆ្នាំផងដែរ។ បញ្ជីឈ្មោះគ្រួសារត្រូវបានរៀបចំទុកជាមុន ដើម្បីកំណត់រកគ្រួសារ និងធានាថាព័ត៌មានដែលប្រមូលសម្រាប់កុមារក្នុងក្រុមអាយុ ៣ ដល់ ៥ ឆ្នាំ និងក្មេងជំទង់ ក្នុងក្រុមអាយុ ១០ ដល់ ១៤ ឆ្នាំ មិនត្រូវបានប្រមូលពីគ្រួសារដដែលឡើយ។